# វាលភក់ទន្លេបាសាក់ A1 & A4i



**ខេត្ត** : កណ្ដាល

**ស្រុក** : គៀនស្វាយ ស្អាង លើកដែក និង កោះធំ

**ផ្ទៃដី ( ហិកតា)** : ៥២.៣១៦

**រយៈកំពស់ ( ម៉ែត្រ)** : ៤ ដល់ ៥

**កូអរដោនេចំណុចកណ្ដាល** : ១១°១៧΄ ជ ១០៥° ០៩΄ ក

### ការពិពណ៌នាទីកន្លែង

តំបន់ IBA នេះ រួមមានតំបន់ដីសើមយ៉ាងធំស្ថិតនៅរវាងទន្លេមេគង្គ និង ទន្លេបាសាក់ ។ រុក្ខជាតិដុះនៅក្នុងតំបន់នេះ រួមមានព្រៃគុម្ពោតលិចទឹក និង វាលស្មៅដែលព័ទ្ធជុំវិញដោយដីកសិកម្ម ។ នៅក្នុងរដូវវស្សា តំបន់នេះត្រូវលិចទឹក ហើយមានលំហផ្ទៃទឹកធំល្វឹងល្វើយគួបផ្សំជាមួយវារីរុក្ខជាតិដុះនៅក្រោម និង ងើបផុតពីផ្ទៃទឹក ព្រមទាំងវារីរុក្ខជាតិដុះគ្របលើផ្ទៃទឹកផងដែរ ។ តំបន់នេះបានទ្រទ្រង់ប្រភេទសត្វស្លាបទឹកមួយចំនួនធំដែលមានដោយសម្បូរ ព្រមទាំងមួយចំនួនតូចនៃប្រភេទស្មោញ ទុងប្រផេះ និង ចាបពូកទ្រូងលឿង ។ លើសពីនេះទៀត តំបន់នេះបានទ្រទ្រង់ចំនួនមួយទៀងទាត់លើសពីមួយភាគរយនៃសត្វតាមជីវភូមិសាស្ត្រនៃប្រភេទរំពេពោះប្រផេះ ។

### ប្រភេទសត្វស្លាបសំខាន់ៗ

| ឈ្មោះខ្មែរ | ឈ្មោះអង់គ្លេស | ឈ្មោះវិទ្យាសាស្ត្រ | លក្ខណៈវិនិច្ឆ័យIBA |
|---|---|---|---|
| ចាបពូកទ្រូងលឿង | Asian Golden Weaver | *Ploceus hypoxanthus* | A1 |
| ទុងប្រផេះ | Spot-billed Pelican | *Pelecanus philippensis* | A1 |
| រំពេពោះប្រផេះ | Whiskered Tern | *Chlidonias hybridus* | A4i |
| ស្មោញ | Darter | *Anhinga melanogaster* | A1 |
| អកត្រីក្បាលប្រផេះ | Grey-headed Fish Eagle | *Ichthyophaga ichthyaetus* | A1 |

### ការគំរាមកំហែងលើជីវៈចំរុះ

អ្នកភូមិប្រាសាទទុយោប្រកបមុខរបរសម្រាប់ជីវភាពរស់នៅរបស់ខ្លួន ដោយពឹងផ្អែកលើធនធានធម្មជាតិនៅក្នុងតំបន់នេះ ហើយសកម្មភាពរបស់ពួកគាត់ គឺជាប្រភពមួយនៃការរំខានដល់សត្វស្លាបទឹកទាំងឡាយ ។ ការគំរាមកំហែងធ្ងន់ធ្ងរនៅក្នុងតំបន់នេះ គឺការប្រមាញ់សត្វស្លាបទឹក ជាពិសេសការប្រើប្រាស់ថ្នាំពុលដើម្បីសំលាប់សត្វ ។

### អនុសាសន៍

ការអនុវត្តន៍ច្បាប់គួរតែធ្វើឡើងឱ្យបានឆាប់រហ័សដោយផ្ដោតលើការប្រមាញ់សត្វស្លាបទឹក និង សកម្មភាពនេសាទខុសច្បាប់នានា ។

### ឯកសារយោង

Akers, P. (2000) *Bird surveys in Cambodia January-March 2000*. Unpublished sabbatical report to RSPB.
Edwards, P. J. (1996) *Cambodia wetlands ornithological survey*. Newmarket: Xenus Ecology.
Edwards, P. J. (1996) Recent waterbird surveys in Cambodia. *Forktail* 15: 29-42.

Goes, F. (1999) Les marais de la plaine des quatre bras. *Cambodia Bird News* 3: 44-51. (In French.)
Goes, F. and Davidson, P. eds. (2002) Recent sightings. *Cambodia Bird News* 9: 47-59.
Mundkur, T., Carr, P., Sun Hean and Chhim Somean (1995) *Surveys for large waterbirds in Cambodia, March-Apri l 1994.* Cambridge, UK: IUCN/SSC.
Scott, D. A. (1992) *Survey of Cambodian wetlands, 26 November to 5 December 1992*. Unpublished report.